~៣~

# ចំណោទស្នេហា

ឯនៅមាត់ទន្លេ ក្នុងខ្ទមលំហែកន្លែងលក់ទឹកដូងខ្ចីនិងសាច់ ងៀត យុត្តិកាកំពុងអង្គុយផឹកទឹកដូងតែម្នាក់ឯង។ ពេល ទំនេរថ្ងៃអាទិត្យ អ្នកកំលោះតែងឆ្លៀតមកអង្គុយស្រូប យកខ្យល់អាកាសនៅទីនេះ ដើម្បីបន្ធូរខួរក្បាលពីការរៀនសូត្រ ខណៈនោះពុទ្ធីស្លៀកពាក់ខោអាវស្ព័រមួយកំប្លេយ៉ាងសង្ហា ជ្រែងហោប៉ៅចុះពីលើម៉ូតូឆ្កែរបស់គេចូលទៅទាញកៅអីអង្គុយទល់មុខយុត្តិកា បែបទំនងបបូរមាត់ញញឹម ជាប់

-សួស្តី! សុំរួមតុជាមួយផងបានទេ?

យុត្តិកាភ្ញាក់ព្រើតពេលងើបមុខឃើញពុទ្ធី គេងក់ក្បាល

-សុំអញ្ជើញ តែខ្ញុំមិនមែនជាអ្នកមានប្រាក់ធូរធារដូចឯងទេ បើត្រឹមទឹកអំពៅមួយកែវប្រហែលជាបាន!

ពុទ្ធីសើចរហូត

-កុំភ័យ ខ្ញុំសុំតែទឹកកកមួយកែវប៉ុណ្ណោះ

អ្នកលក់ធ្វើភ្នែកស្លឹរួចទៅលើកតែទឹកកកមកឱ្យពុទ្ធី កំលោះអ្នកលេងរូបស្អាតដៀងភ្នែកមើលយុត្តិកាបន្តិច

-របួសឯងយ៉ាងម៉េចទៅហើយ?

-បើខ្ញុំស្លាប់ធ្វើម៉េចអាចមកអង្គុយនៅទីនេះបាន?

-នែ! ម៉េចក៏កំបុតកំបុយម្ល៉េះ? ខ្ញុំមានចិត្តចង់រាប់អានឯងជាមិត្តណាំ! ព្រោះយើងមានចរិតខុសគេ! ខ្ញុំចូលចិត្ត!

យុត្តិកាក្រវីក្បាលតិចៗ

-ខ្ញុំទទួលស្គាល់ថាឯងក៏គ្រាន់បើដែរ ដែលមានទឹកចិត្តជាកូនប្រុសហ៊ានស៊ីហ៊ានសង គ្រាន់បើជាងមនុស្សខ្លះអួតខ្លួនថាត្រឹមត្រូវ ថ្លៃថ្នូរតែមិនប្រកាន់ពាក្យសច្ចៈស្មើឯងទេ តែយើងទាំងពីរ រស់ក្នុងពិភពខុសគ្នាស្រឡះខ្មៅហើយនិងស យកពាក្យមិត្តមកប្រើវាប្លែកត្រចៀកពេកទេដឹង? ដើម្បីប្រាក់ឯងស៊ីក៏ហ៊ានធ្វើ នារីដ៏ល្អបរិសុទ្ធម្នាក់ត្រូវខូចឈ្មោះដោយសារឯងអស់ទៅហើយដឹងទេ?

ពុទ្ធីបើកភ្នែកក្រឡង់

-គឺនាង...មែនទេ?

-ចុះមានអ្នកណាទៀត!

ពុទ្ធីសើចស្ងួត

-បើរវល់តែគិតថាគួរធ្វើឬមិនគួរធ្វើ! ខ្ញុំធ្វើម៉េចអាចរស់បានមកដល់ពេលនេះ? ខ្ញុំជាកូនអ្នកក្រ រៀនសូត្របានតិច សំអាងលើកំលាំងនិងដៃទាំងពីរ ដើម្បីរស់ប្រៀបដូចមនុស្សកំពុងលង់ទឹក ស្រវាចាប់ស្អីក៏បានដែរឱយតែតោងជាប់ កុំឱយវាលង់ស្លាប់

-តែឯងអាចផ្លាស់ប្តូរវិធីរកប្រាក់បានដែរតើ ខ្ញុំមើលទៅឯង ឥឡូវនេះ ហ៊ឺហាគ្រប់គ្រាន់ជាងខ្ញុំឆ្ងាយណាស់! ហេតុអ្វីក៏ឯងនៅតែទទួលធ្វើអំពើខុសច្បាប់ ដើម្បីប្រាក់ទៀត!

-ឯងមិនយល់ទេ!ខ្ញុំមានមូលហេតុផ្ទាល់ខ្លួនដែលមិនអាចអ្នកដទៃយល់បាន! ប្រាក់ខែត្រឹមអ្នកមើលការខុសត្រូវក្នុងវង្គសាល មិនអាចបំពេញតាមតំរូវការរបស់ខ្ញុំបានឡើយ

យុត្តិកាប្រែទឹកមុខ

-បើឯងនៅតែជាមនុស្សដូច្នេះ! កុំប្រើពាក្យមិត្តជាមួយខ្ញុំអី! ព្រោះវាដូចជាកំប្លែងពេកហើយ សំរាប់អ្នកដែលមានទស្សនៈផ្ទុយគ្នាស្រឡះនោះ!

-ក្នុង១ជីវិតនេះខ្ញុំមិនដែលសុំអ្នកណាជាមិត្តទេ! ប្រហែលមកពីយើងទាំង២មាននិស្ស័យជាមួយគ្នាដ៏មិនដឹង ទោះជាឯងមិនព្រមទទួលការរាប់អានពីខ្ញុំ! ក៏ខ្ញុំនៅតែចាត់ទុកឯងជាមិត្តហើយអរគុណចំពោះតែទឹកកក១កែវនេះ!

-អូ! ឯងអស្ចារ្យដល់ម្លឹងផង! អញ្ចឹងខ្ញុំក៏អរគុណដែរ ដែលឯងទុកខ្ញុំជាជនទី១ជាមិត្តរបស់ឯង តែខ្ញុំមិនហ៊ានទទួលទេ! លាសិនហើយ!

ឱយថ្លៃទឹកអំពៅរួច យុត្តិកាដើរចេញទៅ ពុទ្ធីតាមមើលយុត្តិការហួតផុតកន្ទុយភ្នែកទាំងញញឹមស្ងួតម្នាក់ឯង។ កំលោះសង្ហាបង្វិលកែវលេងសញ្ជឹងគិតទៅឆ្ងាយ ទឹកមុខគេស្មើធេង គ្មានអ្នកណាអាចដឹងបានទេ! ថាគេកំពុងគិតពីអ្វី? ចេញពីកន្លែងទឹកអំពៅ ពុទ្ធីជិះម៉ូតូសំដៅទៅ វង្គសាលវិមានសួគ៌ ដែលគេធ្វើការជាអ្នកបាំកន្លែងស៊ីផឹក មើលការពាររបៀបរៀបរយរបស់នារីឡង់សេនៅទីនោះ។ចូលដល់បន្ទប់ផ្ទាល់របស់ថៅកែក្មេងរបស់គេឈ្មោះកាណាន។ ពុទ្ធីភ្ញាក់ព្រើត ព្រោះឃើញវ៉ាជីននៅអង្គុយផឹកប៊ីយៀរជាមួយកាណានហើយពុទ្ធីបានស្គាល់ច្បាស់ថាជីនជាគូដណ្តឹងរបស់អ្នកគ្រូពេទ្យម៉ារី ដែលគេចាប់ខ្លួនថ្ងៃមុននោះ។ ជីនជាមិត្តនឹងកាណានយូរហើយ ព្រោះគេជាកូនអ្នកមានទ្រព្យដូចគ្នាហើយមានមុខរបររកស៊ី ដែលមានទំនាក់ទំនងនឹងគ្នា គ្រាន់តែកាណានមានកន្លែងសំរាប់ឱយនារីបំរើអារម្មណ៍។ ចំណែកលោកជេន បើកតែសណ្ឋាគារសំរាប់ស្នាក់ប៉ុណ្ណោះ។ ឃើញពុទ្ធីចូលមកដល់កាណានញញឹមទះស្មាជីន

-នោះហ្ន៎ អ្នកដែលឯងត្រូវឱយរង្វាន់ដល់គេនោះមកដល់ហើយ គេឈ្មោះពុទ្ធី រឿងរ៉ៃតប់ទុកចិត្តលើគេចុះ ឯងអាចពឹងពាក់គេពេលណាក៏បាន! ជីនញញឹមស្រស់ហុតលុយ១០០០$ ហុចឱយពុទ្ធី

-ណេះប្រាក់ឈ្នួលដែលពុទ្ធីបានជួយធ្វើកិច្ចការឱយខ្ញុំថ្ងៃមុននោះ ទោះជាមិនទាន់សំរេចថាបានជោគជ័យ តែខ្ញុំនៅតែតវ៉ារឿងរៀបការជាមួយឪពុកខ្ញុំឱយទាល់តែបាន!

ពុទ្ធីញញឹមស្ងួតរុញលុយទៅឱយជីនវិញ

-ខ្ញុំមិនហ៊ានទទួលទេ ព្រោះខ្ញុំមិនបានទុកនាង១យប់ដូចលោកបញ្ជាហើយរិតតែមិនហ៊ានទទួលទៅទៀត នៅពេលដឹងថាអ្នកដែលជួលឱយខ្ញុំធ្វើដូច្នេះ ជាគូដណ្តឹងរបស់នាងទៅវិញ!

រួចគេងាកមករកកាណាន

-ខ្ញុំទៅធ្វើការរបស់ខ្ញុំហើយលោកថៅកែ!

ពុទ្ធីដើរចេញវិញ ជីនបើបភ្នែកធំៗ ស្ទុះងើបឈរ

-ឈ្លើយមែន! វាគ្រាន់តែជាអ្នកបំរើការងារឱយឯងសោះ មានសិទ្ធិអីមករិះគន់ខ្ញុំ? កាណានក្រវីក្បាលចិត្តៗ

-កុំច្រឡោតអីជីន ពុទ្ធីនេះវាមានចរិតចំលែកណាស់ ម្តងល្អម្តងអាក្រក់ តែវាខ្លាំងណាស់ណា ៣.៤នាក់ ចូលវាម្នាក់មិនចុះទេ យើងសំរបទុកវាប្រើ កុំសន្សំរឿងជាមួយមនុស្សដៃឆៅដូចវាអី! ជីនជ្រួញចិញ្ចើម ខាំមាត់ទប់កំហឹង។

--------------------------------------------

នៅក្នុងបន្ទប់ពេទ្យ ម៉ារីស្លៀកពាក់ខោអាវពេទ្យ កំពុងរៀបចំថ្នាំ នារីពេទ្យមិត្តរួមការងារនាងម្នាក់ចូលមកដល់ សើចដាក់ម៉ារី

-អេ! រី! ឯងទៅជួយមើលអ្នកជម្ងឺបន្ទប់លេខ១២បន្តិចទៅ ទាមទាររកតែអ្នកគ្រូពេទ្យម៉ារីប្រហែលជាឈឺបេះដូងម្នាក់ទៀតហើយ!

-ទុកឱយខ្ញុំទៅបន្តិចមើល បើចំដើលខិល ឱយគេភ្លក់ម្ជុលមុខធំរបស់ខ្ញុំម្តង!

ពួកនាងអស់សំណើចទាំងអស់គ្នា! ម៉ារីរៀបចំម្ជុល និង ថ្នាំយកចូលទៅបន្ទប់លេខ១២ ព្រោះមិត្តនាងប្រាប់ថាគេចង់មកចាក់ថ្នាំកំលាំង គ្មានឈឺអីទេ! ចូលដល់ក្នុងបន្ទប់លេខ១២ បុរសនោះដេកលើគ្រែបែរខ្នងមកក្រៅ នាងក្រមុំដាក់សេរ៉ាំងលើតុក្បាលដំណេករួចហៅគេ

-លោកៗ ក្រែងមកចាក់ថ្នាំមែនទេ?

ពេលគេងាកមុខមក នាងក្រមុំភ្ញាក់ព្រើត គឺពុទ្ធីសោះ គេសើចស្រស់

-សួស្តីអ្នកគ្រូពេទ្យ!

ម៉ារីស្ទុះថយទាំងញាប់ញ័រ

-លោកឯង?

ពុទ្ធីញញឹមតិចៗ

-កុំភ័យ! ខ្ញុំមិនបានគិតអ្វីផ្តេសផ្តាស់ទៀតទេ ខ្ញុំមកចាក់ថ្នាំ អ្នកនាងជាគ្រូពេទ្យត្រូវតែមើលថែខ្ញុំតាមមុខនាទីហើយខ្ញុំមកនេះចង់អរគុណអ្នកនាងដែលមិនប្តឹងពីខ្ញុំ និង សុំទោសចំពោះរឿងដែលកន្លងហួសទៅ! ខ្ញុំធ្លាប់ធ្វើការដើម្បីប្រាក់មែន តែខ្ញុំមិនធ្លាប់ធ្វើឱយនារីណាម្នាក់ខូចឈ្មោះដោយសារខ្ញុំទេ...ទើបតែអ្នកនាងជានារីទី១

ម៉ារីឈរធ្មឹងបន្តិច ទើបឈានចូលយឺតៗ

-ខ្ញុំមិនចង់រំលឹករឿងកន្លងហួសទេ ឥឡូវនេះខ្ញុំចាក់ថ្នាំឱយលោក សុំអញ្ជើញ!

ពុទ្ធីឡើងលើគ្រែពេទ្យដេកផ្អៀងឱយនាងក្រមុំចាក់ថ្នាំឱយ មាត់នៅនិយាយប៉ប៉ោច

-អេ! អ្នកនាង! កុំបួមទឹកចាក់សំឡាប់ខ្ញុំណា!

ម៉ារីញញឹមស្ងួត

-បើលោកខ្លាច មកឱយខ្ញុំចាក់ថ្នាំធ្វើអី?

-ព្រោះខ្ញុំគិតថាអ្នកនាង មិនដាច់ចិត្តសំឡាប់ប្រុសសង្ហាដូចខ្ញុំទេ!

និយាយចប់សឹងមិនទាន់ នាងក្រមុំបុកម្សុលពីប! រួចបួមថ្នាំយ៉ាងលឿន ធ្វើឱយពុទ្ធិចុកស្រែកយ៉ៃ

-អូយ! អ្នកនាងបុកម្សុលដូចចាក់គោ បួមថ្នាំលឿនដូចទឹកធ្លាក់ពីជ្រោះ បែបនេះចង់សំឡាប់អ្នកជម្ងឺមែនទេ?

ម៉ារីទ្រាំមិនបានលួចសើចដែរ តែនាងមិនខ្វីឆ្លើយ ពេលចាក់ថ្នាំរួចម៉ារីប្រមូលម្សុលនិងថាសថ្នាំបំរុងលើកចេញ តែពុទ្ធិស្ទុះមកពាំងមុខនាងជាប់

-ឈប់សិន! ដែលខ្ញុំមករកអ្នកនាងពេលនេះ ព្រោះខ្ញុំមានរឿងមួយចង់ប្រាប់ឱយអ្នកនាងបានដឹង ទោះអ្នកនាងជឿឬមិនជឿក៏ដោយ ថ្ងៃនោះខ្ញុំគ្មានបំណងអាក្រក់លើអ្នកនាងទេ ខ្ញុំគ្រាន់តែទទួលប្រាក់ពីគេ ដោយព្រមចាប់ខ្លួនអ្នកនាង ឃុំទុកតែមួយយប់តែប៉ុណ្ណោះ កាលណោះខ្ញុំក៏មិនយល់បំណងអ្នកជួលខ្ញុំដែរ ទើបតែឥឡូវដឹងថាអ្នកជួលខ្ញុំនោះគឺជាគូដណ្ដឹងរបស់អ្នកនាង ដែលមានបំណងឱយអ្នកនាងខូចឈ្មោះ មនុស្សដូចគេនោះមិនសមនឹងអ្នកនាងព្រមរៀបការជាមួយទេ! អ្នកនាងប្រាកដជាខកចិត្តមិនខាន! ហើយខ្ញុំក៏សោកស្ដាយបំផុតដែលខ្ញុំព្រមទទួលធ្វើកិច្ចការនេះឱយគេ!

និយាយចប់ពុទ្ធិបោះជំហ៊ានចេញទៅយឺតៗ ទុកឱយស្រស់ម៉ារីនៅឈរភាំងលែងកំរើក ស្រីខាំមាត់ទប់ទឹកភ្នែក ដែលដក់ពេញក្នុងកែវភ្នែកស្រីមិនឱយហូរធ្លាក់ ដោយក្ដីឆ្អែតណែនហួសប្រមាណ ព្រោះនាងមិនទឹកស្មានថា ជីនហ៊ានជាន់ឈ្លីកិត្តិយសនាងដល់ម្លឹង ស្រីខាំមាត់សំរេចចិត្តថា ពេលរៀបការបំពេញមុខឪពុករួច នាងនឹងរត់ចេញទៅឱយឆ្ងាយ ដាច់ខាតមិនរួមរស់ជាមួយជីនទេ!ឥឡូវជិតដល់ថ្ងៃនាងរៀបការទៅហើយ ឱយវាទៅតាមដំណើរសិនទៅចុះ ។ ចេញពីធ្វើការម៉ារី ទៅអង្គុយលេងនៅសួនសាធារណៈមាត់ទន្លេម្នាក់ឯង នាងចង់សំរួលចិត្តឱយបានស្ងប់ ព្រោះពេលនេះទុក្ខសោកកំពុងរួបរិតពេញក្នុងដួងចិត្តស្រី នាងល្អអង្គុយលើបង់ថ្មភ្លឹកទៅឆ្ងាយ ។ យុត្តិកាឆ្លៀតពេលក្រៅម៉ោងរៀន មកធ្វើការរួចលប់លាងដៃជើង ឡើងមកលើច្រាំងវិញ ក៏ក្រឡេកឃើញម៉ារី មាណពដើរដំរង់មករកនាង

-អ្នកនាង! ម៉េចក៏មកអង្គុយតែម្នាក់ឯងអញ្ចឹង

ម៉ារីបានជួបយុត្តិកា នាងហាក់ដូចជារំភើបក្នុងចិត្តណាស់ ញញឹមស្រាលដាក់អ្នកកំលោះ

-បងកុំភ័យ ខ្ញុំគ្មានគ្រោះថ្នាក់អ្វីទៀតទេ គេម្នាក់នោះមិនត្រូវការចាប់ខ្ញុំទៀតឡើយ គេថែមទាំងប្រាប់ខ្ញុំតាមត្រង់ថា អ្នកដែលជួលគេធ្វើបែបនេះគឺជីន ព្រោះគេចង់រកលេសផ្ដាច់ពាក្យពីខ្ញុំ!

នរៈសង្ហាធ្វើភ្នែកស្លី អង្គុយចុះក្បែរនាងក្រមុំធ្វើមុខដូចមិនអស់ចិត្ត

-ជីន? គេ...គេ ធ្វើដល់ម្លឹងឬ?

-បងមិនមែនមិនយល់ទេ ជីនគេចូលចិត្តអ្នកនាងណាគ្រីណាស់! ខ្ញុំមិនចង់រៀបការទេ! តែមិនអាចជំទាស់នឹងលោកប៉ាបាន!

ឈឺចិត្តពេកនិយាយបណ្ដើរទឹកភ្នែកស្រីស្រក់ហូរជោកថ្ពាល់ ។ យុត្តិកាដកដង្ហើមធំហួតកូនកន្សែងហុចឱយនាង

-ខ្ញុំជាអ្នកក្រៅគ្មានយោបល់អ្វីអាចជួយអ្នកនាងបានទេ...អ្នកនាងកុំព្រួយពេកគ្មានរឿងអ្វីដែលមនុស្សដោះស្រាយមិនបានឡើយ!

ម៉ារីទទួលកូនកន្សែងមកជូតទឹកភ្នែក ពេលនោះជីនជិះឡានជាមួយណាត្រីកាត់តាមទីនេះ ពួកគេចេញពីសណ្ឋាគាររបស់ជីន គេសុំខ្លួនជូននាងក្រមុំទៅផ្ទះ ។ ជីនឃើញយុត្តិកា និង ម៉ារីនៅអង្គុយក្នុងសួនសាធារណៈជាមួយគ្នាបានឱកាសភ្លាម

-អ្នកនាងឃើញទេ? តាំងពីបានជួយគ្នាម្តងនោះម៉ារីប្លែកណាស់ ពួកគេតែងស្កាត់ជួបគ្នា! វីមិនបានស្រឡាញ់ខ្ញុំទេ យើងបង្ខំចិត្តរៀបការតាមតែចាស់ទុំ តើវាមានន័យអ្វីទៅ?

ណាត្រីធ្លាក់ទឹកមុខ សំឡឹងទៅយុត្តិកាដោយក្តីប្រច័ណ្ឌ

-បើដឹងថារៀបការគ្មានន័យ ម៉េចក៏បងជីនមិនដោះស្រាយជាមួយអ្នកនាងវីឱយច្បាស់លាស់ទៅ?

-មកពីលោកប៉ា អាងសង្កត់ខ្ញុំរឿងមិនចែកមតក ហើយខ្ញុំមិនចង់ឱយនារីដែលខ្ញុំពេញចិត្តត្រូវមករស់នៅជាមួយខ្ញុំដែលមានតែបាតដៃទទេឡើយ ទើបខ្ញុំព្យាយាមដោះស្រាយរឿងនេះតាមសំរួល

ដឹងថាគេនិយាយសំដៅនាង មាណវីធ្វើអ៊ឹមអៀនមិនចេញស្តី ជីនបើកឡានហួសទៅលួចដៀងភ្នែកមើលមុខណាត្រីបណ្តើរ

-ហើយខ្ញុំសង្ឃឹមថា ណាត្រីព្រមយល់ពីការពិបាកនិងជំរៅបេះដូងខ្ញុំ! ទោះយ៉ាងណាខ្ញុំនឹងដោះស្រាយរឿងខ្ញុំនិងម៉ារីឱយទាល់តែបាន!

-ខ្ញុំរង់ចាំមើលបងបាន! តែខ្ញុំសុំបញ្ជាក់ដាច់ខាត ខ្ញុំមិនធ្វើខ្លួនជាមនុស្សទីពទេ បើបងមិនអាចទំនេរជ្រះស្រឡះទេ រឿងអ្វីក៏យើងមិនបាច់និយាយគ្នាទៀតដែរ!

ជីនញញឹមស្រស់ លូកដៃមកក្តោបដៃណាត្រីថ្នមៗ ងក់ក្បាលជំនួសចំលើយ។ លោកសានឃើញជីនជូនកូនស្រីមកដល់ផ្ទះ លួចមើលពីមាត់បង្អួចមកញញឹមស្រស់ ក្នុងចិត្តសង្ឃឹមទាំងស្រុងថាបានជីនពេញចិត្ត គឺជាសំណាងល្អរបស់កូនស្រីហើយ ឱយតែគេមិនពេញចិត្តម៉ារីគេច្បាស់ជាដោះស្រាយរឿងត្រូវរៀបការនោះបានយ៉ាងប្រាកដ ។

---------------------------

នៅតែ១អាទិត្យទៀតដល់ថ្ងៃរៀបការជីននិងម៉ារីហើយ ស្រាប់តែថ្ងៃនេះម៉ោងប្រហែល៩ព្រឹក លោកយ៉េតចូលមកក្នុងកន្លែងក្រុមហ៊ុនទះតុលោកស្មៀនសានម៉ាំងៗទាំងខឹងច្រលោតមុខឡើងខ្មៅអែ ធ្វើឱយផ្អើលបុគ្គលិកដែលធ្វើការនៅក្នុងក្រុមហ៊ុន

-ហ៊ឹះជេនគេនៅឯណា! ខ្ញុំចង់ជួបគេឥឡូវនេះ! បញ្ជីទូកកំពង់សោម ខ្ញុំចុះឆែកឆេរផ្ទាល់២ឆ្នាំនេះ ធ្វើបញ្ជីបន្លំខ្ញុំអស់ប្រាក់រាប់លានបាត បែបនេះសមជាមិត្តភ័ក្តិដែរទេ?

លោកសានធ្វើអេះអុញ!

-ថៅកែនៅផ្ទះឯណោះ ថ្ងៃនេះគាត់មិនបានមកក្រុមហ៊ុនទេ!

-ល្អ! ទុកឱយខ្ញុំទៅជួបគេនៅផ្ទះ! និយាយគ្នាឱយដឹងសខ្មៅម្តង!

លោកយ៉េតដើរចេញរឹងទាំងម៉ូម៉ៅ លោកសានងាកប្រាប់បុគ្គលិកដែលផ្ទើលមើលមកលាន់

-នាំគ្នាធ្វើការទៅខ្ញុំ ទៅមើលថៅកែមួយភ្លែត ច្បាស់ជាឈ្លោះគ្នាខ្លាំងមិនខាន បើលោកយ៉េតខឹងម្លឹងនោះ!

រួចលោកសានប្រញាប់បើកឡានចេញទៅតាមក្រោយលោកយ៉េតភ្លាម។ មកដល់ផ្ទះលោកជេន នាងសឿនស្រីបំរើទើបនិងយួរកន្ត្រកមកពីផ្សារទិញម្ហូប លោកសានសួរនាងបំរើ!

---

-ឃើញលោកយ៉េតមករកលោកថៅកែទេសឿន?

-ចាំឃើញ គាត់មកដល់ដំណាលខ្ញុំដែរ រត់ឡើងទៅបន្ទប់លោកប្រុសបាត់ហើយ មុខដូចជាខឹងខ្លាំងណាស់ តើមានរឿងអីនឹងលោកស្មៀន?

-ទុកខ្ញុំឡើងទៅមើលសិន!

លោកសានឡើងទៅបន្ទប់ការងាររបស់លោកជេននៅជាន់ទី១ សំរាប់លោកជេនពិនិត្យបញ្ជីឬចុះហត្ថលេខាផ្សេងៗ ពេលណាលោកមិនបានទៅក្រុម-ហ៊ុន។ លោកសានចូលទៅក្នុងបន្ទប់យ៉ាងប្រញាប់ ស្រាប់តែស្រឡាំងកាំងជ្រុះបញ្ជីពីដៃព្រោះឃើញលោកជេនអង្គុយផ្អែកកៅអី នៅទ្រូងមានកូនកាំបិតមួយដោយឆ្អឹង ឈាមហូរជោគឥដ្ឋចំណែកលោកយ៉េតដៃមានប្រឡាក់ឈាម កំពុងឈរភាំង លើកដៃមើលដោយភិតភ័យនៅមាត់បង្អួច ទ្រុងសេកចេះនិយាយដែលលោកជេនស្រឡាញ់បំផុតព្យួរនៅទីនោះសេកឆ្លាតហាក់ភ័យយ៉ាងខ្លាំងនិងព្រឹត្តិការណ៍ដ៏គួរឱយខ្លាចចំពោះម្ចាស់វា ។ សេកស្រែកទទះស្លាប ហក់ចុះហក់ឡើងពេញទ្រុង វាស្រែកដដែលៗ

-ឯង?... ឯង?...ហ៊ុះ!ឯង

លោកសានភ័យញ័ររត់ទៅទូរស័ព្ទ ប្តឹងប៉ូលីសមកជាបន្ទាន់ឱយឃាត់ខ្លួនលោកយ៉េតភ្លាម។ លោកយ៉េតប្រកែកដាច់ខាត ថាលោកមិនបានសំឡាប់លោកជេនទេ។ នៅក្នុងស្នាក់ការប៉ូលីស លោកសាន ជីនអង្គុយម្ខាង...លោកយ៉េតដៃជាប់ខ្នោះ មុខស្លេកស្លាំង ចំណែកជីនមុខខ្មៅ ខាំមាត់សំឡក់លោកយ៉េតពេញដោយកំហឹង ព្រោះលោកយ៉េតនៅតែបដិសេធថាលោកមិនបានសំ-ឡាប់លោកជេនទេ លោកខឹងរឿងគេបំបាត់ភាគហ៊ុនមែនតែមិនដល់ថ្នាក់សំ-ឡាប់គ្នាឡើយ។ ពេលដែលលោកចូលទៅដល់បន្ទប់លោកជេនឃើញ គាត់អង្គុយផ្អែកកៅអីបែរខ្នងមកក្រៅ លោកក៏ស្ទុះទៅទាញឱយបែរមកនិយាយគ្នាបែរជាឃើញលោកជេនត្រូវគេធ្វើឃាដ ហើយដៃលោកក៏ប្រឡាក់ឈាមលោកជេនតែម្តងទៅ។ ទោះជាយ៉ាងនេះក្តី ជីននិងលោកសានចោទទាំងស្រុងថាគ្មានអ្នកណាក្រៅពីលោកយ៉េតទេជាឃាតក។ ចំណែកខាងប៉ូលីស គេសង្ស័យថាលោកយ៉េតជាន់ដានឃាតក តែបើរកភស្តុតាងអ្វីមកបញ្ជាក់មិនបានទេនោះលោកយ៉េតត្រូវតែជាប់ចោទទាំងស្រុងហើយត្រូវជាប់ពន្ធនាគារ២០ឆ្នាំ។ វ៉ា-ជីនធ្វើបុណ្យឱយឪពុក ៧យប់ ៧ថ្ងៃសមនិងកិត្តិយសគ្រួសារគេ ទោះជីនធ្លាប់រឹងរូសខ្លះជាមួយឪពុក តែគេស្រឡាញ់ឪពុកណាស់ ព្រោះមានតែ២នាក់ឪពុកកូន

ឥឡូវអ្នកត្រូវរស់នៅកំព្រាម្នាក់ឯង ទោះជាមានទ្រព្យច្រើនប៉ុណ្ណា តែវាហេងហាងរកថាមិនត្រូវ ជីនស្រក់ទឹកភ្នែកពេលធ្វើបុណ្យសពឪពុក ដែលតាំងពីដើមមកអ្នកមិនដែលស្រក់ទឹកភ្នែក១ដំណក់ឡើយ ។ណាត្រីឃើញជីនកើតទុក្ខ ក៏មកអង្គុយកំដរគេជួយលួងលោម យុត្តិកាក៏មកជួយបំរើភ្ញៀវក្នុងពិធីបុណ្យនេះ បានឃើញណាត្រីហាក់ដូចជាយកចិត្តទុកដាក់និងជីន អ្នកកំលោះមានទឹកមុខស្រងូតគេចចេញទៅក្រោយ ព្រោះមិនចង់ឃើញនាងស្និទ្ធស្នាលនិងប្រុសដទៃ ។ មួយរយៈនេះមាណពសំគាល់ឃើញថាណាត្រី ហាក់ព្រងើយកន្តើយនិងអ្នក តែអ្នកក៏មិនដឹងថាមូលហេតុអ្វីនោះដែរ... ។ លោកមឿននិងម៉ារីក៏បានមកជួយក្នុងពិធីបុណ្យនេះយ៉ាងពេញដៃពេញជើងទាល់តែរួចរាល់ ។ ប៉ុន្តែនៅពេលដែលធ្វើបុណ្យសពឪពុកគេរួច ជីនបែរជាទូរស័ព្ទមករកលោកមឿនផ្តាច់ទំនាក់ទំនងរវាងគេនឹងម៉ារីទៅវិញ ព្រោះពេលនេះអស់ពីឪពុករបស់គេទៅហើយ ជីនគ្មានអ្វីទើសទៀតទេក្នុងរឿងរៀបការបង្ខំចិត្តនេះ

-លោកពូ ខ្ញុំមានរឿងចង់ជំរាប! សុំពូអភ័យទោសឱយខ្ញុំផងចុះ ការរាប់អានរវាងចាស់ៗ មិនអាចជាចំណង សំរាប់ក្មេងៗនោះទេ ពិធីរៀបការខ្ញុំនិងម៉ារីមិនមែនផ្អាកត្រឹមរួចរាល់បុណ្យសពលោកប៉ាឡើយ! ខ្ញុំ...ចង់..

លោកមឿនតបយ៉ាងរហ័ស

-មិនបាច់និយាយច្រើនទេជីន! ម៉ារីក៏មិនចង់រៀបការជាមួយឯងដែរ! ពូធ្លាប់គិតយល់ដល់ការរាប់អានរបស់ចាស់ៗ ឥឡូវអស់ពីឪពុកឯងទៅហើយទំនាក់ទំនងកន្លងមកចាត់ទុកថាចប់ចុះ

លោកបិទទូរស័ព្ទភ្លាម ព្រោះអន់ចិត្តនឹងជីន ម៉ារីស្តាប់ឮ ចូលមកអង្គុយក្បែរឪពុកទាំងទឹកមុខរីករាយ

-លោកប៉ា?

លោកមឿនឈ្លីក្បាលកូនតិចៗ

-ប៉ាឈប់បង្ខំចិត្តកូនទៀតហើយ សុខចិត្តបង់កិត្តិយសពេលនេះចុះ កុំឱយកូនត្រូវគ្រាំចិត្ត១ជីវិត!

នាងក្រមុំផ្តេកក្បាលក្នុងរង្វង់ដៃឪពុកដោយរំភើបត្រេកអរ ព្រោះនេះជាបំណងប្រាថ្នារបស់នាង ។ ពេលនេះមានសេរីភាពដូច្នេះជីនក៏រីករាយណាស់ដែរ គេកាន់តែស្និទ្ធស្នាលនិងណាត្រីរហូតទិញឡានថ្មី១គ្រឿងយកមកឱយនាងក្រមុំសំរាប់ជិះទៅធ្វើការខ្លួនឯង និង គ្រឿងពេជ្រមួយកំប្លេទៀតផង ។ ណាត្រីត្រូវសំភារៈទំនើបៗអូសទាញហើយ នាងពេញចិត្តនឹងជីនខ្លាំងឡើងៗ រហូតភ្លេចយុត្តិកាដែលនៅនឹងមុខបង្កើយ ។ ណាត្រីព្យាយាមគេចមិនរវីរវល់ជាមួយយុត្តិកាទៀតទេ ហើយក៏ធ្វើដូចជាភ្លេចទាំងស្រុងថា នាងធ្លាប់បានប្រគល់ផ្កាណាត្រីមួយទងដំណាងទាំងចិត្ត ទាំងបេះដូងទៅឱយយុត្តិកា រួចហើយក៏ជាន់ឈ្លីផ្កាមួយទងនោះ ឱយខ្ទេចខ្ទាំគ្រាំគ្រាដល់ដួងចិត្តកំលោះទុរគតិម្នាក់ដែលគ្មានអ្វីទាំងអស់ជាទីអាង ក្រៅពីបេះដូងស្មោះស្ម័គ្រភក្តី ។ យុត្តិកាមិនមែនមិនយល់ទេ អ្នកឈឺផ្សាក្នុងចិត្តណាស់ ដែលស្នេហ៍គ្រាដំបូងក្នុងចិត្តរបស់អ្នកបរាជ័យ មនោ-សញ្ចេតនាត្រូវបាត់បង់ អតីតកាលត្រូវងងឹតសូន្យសុង្យ ។ បច្ចុប្បន្នត្រូវចុកចាប់ ទោះណាត្រីមិនទាន់និយាយអ្វី តែអ្នកអាចយល់ច្បាស់ដោយខ្លួនឯង ហើយត្រូវ

ត្រៀមកាយត្រៀមចិត្តទទួលការបាត់បងស្នេហ៍គ្រាដំបូង ពីពេលនេះនិងរហូតតទៅ។

ទោះជាមានទុក្ខក្រៀមក្រំក៏យុត្តិកាមិនយកស្នេហាមករំខានការសិក្សារបស់អ្នកដែរ ល្ងាចថ្ងៃសៅរ៍នេះ មាណពសង្ហាឈ្មោះតយកមេរៀនទៅអង្គុយមើលនៅខ្ទមលក់បាយមាត់ទន្លេកន្លែងដាច់ឆ្ងាយពីគេពីឯងបន្តិច នៅក្បែរនោះមានកន្លែងលក់ប៊ីយេរ និង គ្រឿងក្លែម បុរសពីរនាក់កាត់សក់ខ្លីផាត់ខ្លួរច្រូងទៅលើមានឬកពាក្រក្មេងក្អាងផឹកស៊ីឆ្កាដៃឆ្កាជើង កំពុងជល់កែវស្រវឹងងល់។ នៅទីនោះតែយុត្តិកាមិនរវល់ឡើយ ខំភ្ជង់អារម្មណ៍អានសៀវភៅព្រោះជិតដល់ពេលប្រឡងចេញទៅហើយ ខណៈនោះមានកំលោះស្ដើម្នាក់អាយុប្រហែល២០ឆ្នាំ មុខមាត់ប្រឡាក់ស្រមូស ខោអាវចាស់ពភ្លក់រត់មកពីណាទេទាំងរហន់ទៅជល់តុពួកអ្នកផឹកពីរនាក់នោះ ធ្វើឱ្យកំពប់ប៊ីយេរប្រឡាក់ខោអាវគេអស់ នាងផ្កុំនិងផនស្ទុះរើបក្របួចអាវក្មេងប្រុសនោះប្រុងទះ ២,៣ដៃ ព្រោះកំពុងស្រវឹងស្រាប់ផង តែកំលោះតូចនោះរត់ទៅពួនក្រោយខ្នងយុត្តិកាស្រែកអង្វរឱ្យអ្នកកំលោះជួយផង

-លោកបង១ ជួយខ្ញុំផង មានមនុស្សចាស់ចង់វ៉ៃក្មេង!

យុត្តិកាងើបឈរពាំងមិនឱ្យពួកគេវ៉ៃកំលោះទូចច្រម៉ក់នោះ

-ឈប់សិនបងប្រុសវានៅក្មេងមិនដឹងអីទេ ពួកបងកុំប្រកាន់នឹងក្មេងធ្វើអី

ផ្កុំបើកភ្នែកក្រឡោត

-ហើយឯងជាស៊ីដែរ? មកអះអាងវានេះ? ក្បាលកញ្ចាស់ បើធ្វើប្ដីគេក៏បានទៅហើយ ក្មេងស៊ីទៀត! ឯងមើលនែ៎១ វាធ្វើឱ្យប្រឡាក់អាវយើងខូចអស់ទៅហើយ! ថយចេញ!

យុត្តិកានៅតែរាំងជាប់

-តែពួកបងទៅធ្វើបាបក្មេងសមដែរទេ? រឿងបន្តិចបន្តួចយើងជាខ្មែរដូចគ្នា ហេតុអ្វីក៏អត់អោនឱ្យគ្នាមិនបាន?

ផ្កុំខឹងច្រលោត ស្ទុះដាល់ចំកញ្ចប់មាត់យុត្តិកាមួយដៃចេញឈាមរីម១តែម្ដង ក្មេងកំលោះនោះបើកភ្នែកធំ១ស្ទុះមកចាប់ដៃយុត្តិកាទាំងភិតភ័យ

-លោកបង?

ផ្កុំចង្អុលមុខយុត្តិកា

-ម៉េចមួយដៃនេះយ៉ាងម៉េចដែរ? យើងចង់ប្រដៅក្មេងនេះ ឯងកុំមកលូកលាន់ឱ្យសោះ!

អ្នកកំលោះជូតឈាម តបទាំងម៉ឺងម៉ាត់

-ទោះយ៉ាងណាក៏ខ្ញុំមិនឱ្យពួកឯង ធ្វើបាបក្មេងដែរ!

កំលោះតូចនោះហាក់រំភើបចិត្តដែរ ឈរសំឡឹងយុត្តិកាភាំង ពេលដែលផ្កុំនិងផនឈានចូលមូដៃអាវប្រុងវ៉ៃយុត្តិកានោះ ពុទ្ធីជិះម៉ូតូមកដល់ល្មម។ គេដោះវ៉ែនតាខ្មៅញាក់មុខដាក់យុត្តិកា

-សួស្ដីសំឡាញ់! អាំ! រួចមាត់ឯងកើតស៊ី?

ផ្កុំនិងផនស្ទុះមករកពុទ្ធីរបៀបគោរព

-លោកបង!

ពុទ្ធីជ្រួញចិញ្ចើមមើលមុខពួកគេទាំងពីរនាក់

-ពួកឯងវៃគេមែនទេ?

-បាទ! មកពីវានេះព្រហើនពេក...ខ្ញុំ...ក៏

ពុទ្ធីរាដៃ

-បញ្ចប់ត្រឹមនឹងបានទេ? ព្រោះគេនេះជាមិត្តរបស់ខ្ញុំ!

-សុំទោស១ ខ្ញុំមិនបានដឹងថាគេជាមិត្តលោកបងទេ!

-ពួកឯងល្មមទៅកន្លែងហើយ ចៅកែកំពុងសួររកឯណោះ

-បាទ១!

ពួកគេនាំគ្នាចេញពីទីនេះយ៉ាងលឿន កំលោះច័ន្ទទះដៃសរសើរ

-អេ! លោកបងម៉ូតូផ្ដែពិតជាអស្ចារ្យមែន! អុះលោកបងឈឺខ្លាំងទេ

ច័ន្ទស្ទុះទៅស្ទាបមាត់យុត្តិកា ធ្វើឱ្យចំកន្លែងឈឺ អ្នកកំលោះស្រែក អួយ ច័ន្ទរលាស់ដៃញាប់ស្អេក

-សុំទោស១

ពុទ្ធីសើចញឹម១

-យ៉ាងម៉េចទៅហើយសំឡាញ់

យុត្តិកាស្ទាបមាត់ដែលហើមស្អុល

-គ្នារបស់ឯងជាអ្នកវៃខ្ញុំ! តែឯងជាអ្នកជួយ តើខ្ញុំគួរជេរឯងឬក៏អរគុណ ឯង?

ពុទ្ធីសើចខឹកច្រត់ដៃលើចង្កូតម៉ូតូយ៉ាងសង្ហា

-ដំបូងឯងជេរខ្ញុំរួចអរគុណខ្ញុំជាក្រោយទៅណា! រស់នៅក្នុងជីវិតនៃកំលាំងដៃ វាម៉្យាងដែរ! ឯងឃើញទេ? ខ្ញុំនិយាយតែមួយម៉ាត់ អ្វី១ក៏ចប់យ៉ាងស្រួល បើអាងលើសច្ចៈភាពនិងយុត្តិធម៌របស់ឯងនោះ ចំណេញតែបែកមាត់!

-ឯងកុំចង់តាំងខ្លួនជាអ្នកខ្លាំងក្នុងអំពើបាបធ្វើអី ព្រោះវាគ្មានលទ្ធផលល្អទេ! ចំណែកពាក្យដែលឯងអះអាងថាខ្ញុំជាមិត្តនោះ ខ្ញុំទទួលមិនបានឡើយ!

និយាយចប់ យុត្តិកាដើរចេញរ៉ឹង ពុទ្ធីតាមមើលយុត្តិកាទាំងក្រវីក្បាលសើចញឹម១ ច័ន្ទរត់តាមពីក្រោយយុត្តិកាតត្រុក

-អេ! លោកបង! ចាំខ្ញុំផង! ចាំផង!

មាណពរូបស្អាត ងាកមើលកំលោះល្អិតនោះទ្រង់ឆ្ងល់

-ឯងដើរតាមបងធ្វើអី?

ច័ន្ទជាស្រីក្រមុំតែងខ្លួនជាប្រុស នាងពាក់សក់ខ្លីដូចសក់ជប៉ុន មើលទៅដូចកូនប្រុសខ្លាំងណាស់ សមនិងឫកពានាងរប៉េសរបូន រឹងប៉ឹងមិនដូចស្រីធម្មតាផងហើយយុត្តិកាមិនបានចាប់ភ្លឹកទៀត គេគិតថានាងប្រុសដែលមានចរិតខ្លះដូចស្រី របៀបប្រុសចរិតខ្ចីយមួយចំនួនប៉ុណ្ណោះ។ ច័ន្ទរត់មកតោងដៃអ្នកកំលោះជាប់ វាចាទាំងរលីងរលោងទឹកភ្នែក

-លោកបងឱ្យខ្ញុំសុំទៅនៅជាមួយផង ខ្ញុំចេះធ្វើការងារសព្វបែបយ៉ាង មិនថាការងារប្រុសឬស្រីមិនបំបង់បាយបងទេ! ខ្ញុំកំព្រាឪពុកត្រូវម្ដាយចុងវៃធ្វើបាបរបួតទើបខ្ញុំរត់ចេញពីផ្ទះមកឥឡូវខ្ញុំអត់បានញុំាបាយ២ថ្ងៃហើយ!

អ្នកកំលោះសំឡឹងមុខមាត់ស្រម៉ករបស់ច័ន្ទដោយក្ដីអាណិត

-ហ៊ឺ! សព្វថ្ងៃបងក៏សុំផ្ទះបងប្អូនស្នាក់ដែរ! តែណ្ហើយចុះចាំបងនាំឯងទៅសុំលោកពូក្រែងគាត់ត្រូវការ អ្នកជួយថែសួនជំនួសកិច្ចការមីងចុងភៅ ខ្លះ!

ច័ន្ទអរណាស់ សើចស្ញាញសំពះយុត្តិកាញាប់ដៃ

-អរគុណបង! អរគុណ! បងពិតជាចិត្តល្អមែន! ខ្ញុំឈ្មោះអាច័ន្ទ បងហៅឈ្មោះខ្ញុំទៅស្រួលជាង

យុត្តិកាទះស្មាច័ន្ទញញឹម

-កុំសំពះបងអី! ព្រោះបងមិនធ្លាប់មានអ្នកណាសំពះបងទេ មានតែបងសំពះគេ! តោះយើងល្មមទៅហើយ!

ច័ន្ទតោងដៃយុត្តិកាជាប់ដោយទឹកមុខរីករាយ។ យុត្តិកានាំច័ន្ទទៅសុំលោកសាន ឃើញច័ន្ទល្មមប្រើការបានអាចជួយមើលថែទាំចាំផ្ទះសំបែង ហើយសុំតែបាយមួយឆ្អែត មិនទាមទារប្រាក់ខែផងលោកសានក៏ព្រមទទួលឱយច័ន្ទនៅជាមួយហើយឱយទៅសំរាកក្នុងបន្ទប់ជាប់ចង្ក្រានបាយជាមួយយុត្តិកា។

◆◆◆◆◆◆◆

~៤~

# សែនអាល័យ

ខ្យល់ជំនោរនិរតី បក់ត្រសៀកហាក់ចង់បបោសអង្អែលទងផ្កាចំរុះពណ៌នៅក្នុងសួនឱយទោរទន់រេរាំប្រណាំងគ្នា បង្កើតជារបាំផ្កាធម្មជាតិយ៉ាងចំឡែក តែកំលាំងខ្យល់ក៏បានធ្វើឱយស្រទាប់ផ្កាធ្លាក់រុះរោយ រសាត់អណ្តែតពេញទីធ្លាប្រៀបដូចផ្កាស្លាជូនពរ ដល់គូស្នេហ៍ថ្មី ក្នុងសួនផ្កាណាគ្រី រ៉ាជីននិងនាងក្រមុំណាគ្រីកំពុងបណ្ដើរគ្នាត្រសងមើលទៅទន់ភ្លន់ហើយស្និទស្នាលណាស់ ស្រស់ស្រីងើបសំឡឹងមុខជីន

-បងបានរសាយទុក្ខខ្លះហើយមែនទេ?

ជីនងក់ក្បាលតិចៗ

-ខ្ញុំនៅមានកិច្ចការច្រើនណាស់ ដែលត្រូវធ្វើជំនួសលោកប៉ា! ខ្ញុំត្រូវតែរឹងប៉ុង មិនឱយលោកប៉ាអស់សង្ឃឹមទេ! ថ្ងៃនេះខ្ញុំចង់មកប្រាប់មុំថាខ្ញុំបានជ្រះស្រឡះនិងម៉ារីហើយ! (គេប្តូរពាក្យហៅនាងក្រមុំបញ្ជាក់នូវភាពស្និទស្នាលរបស់ពួកគេ ហើយកន្លងមកឈ្មោះនៅផ្ទះរបស់ណាគ្រីមានតែយុត្តិកាទេ ដែលហៅដូច្នេះ)

ណាត្រីដកដង្ហើមធំបន្តិច

-បងធ្វើដូច្នេះរហ័សពេកទេដឹង?

-ម៉ារីគេពេញចិត្ត បងជីដូនមួយរបស់មុំ! អូនក៏ឃើញស្រាប់!បើគង់តែចប់ដដែល ហេតុអ្វីក៏យើងត្រូវអូសបន្លាយពេលវេលាឱ្យវាកន្លងទៅដោយគ្មានន័យនោះ?

យុត្តិកាលបមើលគេទាំងពីរពីចំងាយកំបាំងនិងគុម្ពផ្កា ភាពស្ថិតស្ថាលដែលមុំសម្តែងទាំងកាយវិការនិងទឹកមុខ ធ្វើឱ្យយុត្តិកា ឈឺផ្សាក្នុងចិត្តពន់ប្រមាណ ដៃគេទាំងពីរក្តាប់ចូលគ្នាយ៉ាងណែនពង្រឹងចិត្តខ្លួនឯង (យុត្តិអើយ គេមានអ្វីៗប្រសើរជាងឯងគ្រប់យ៉ាង មុំជ្រើសរើសអ្វីដែលជាសេចក្តីសុខសំរាប់នាងហើយ ឯងគួរតែជួយត្រេកអរនាង...)។ ជីននិងណាត្រីនាំគ្នាឡើងទៅលើផ្ទះហើយ។ យុត្តិកាកំពុងឈរភ្លឹកម្នាក់ឯងស្រាប់តែឮសំលេងសើចខឹក គេងាកទៅឃើញច័ន្ទកំពុងខ្ទប់មាត់សើចនៅក្រោយគម្ពោតផ្កាក្បែរនោះ អ្នកកំលោះបើកភ្នែកធំៗ

-ឯងសើចអី?

ច័ន្ទវៃដៃចង្អុលតាមគុម្ពផ្កា

-បាទ! ខ្ញុំសើចនឹងមេអំពៅ១គូដេញកៀងគ្នា រួចហើយកន្លង់មួយ វរល់តែហោះទ្រុយៗឃីតពេក ក៏ដណ្តើមគូមិនទាន់គេ!

ថារួចច័ន្ទរត់ចេញទៅបាត់ យុត្តិកាក្រវីក្បាលហួសចិត្ត

-ក្មេងនេះ ឆ្លាតហួសក្បួនហើយទេដឹង?

ពេលយប់រៀបចូលគេង ច័ន្ទងូតទឹកស្រួលបួលស្លៀកខោកុយឡុតត្រឹមជង្គង់របៀបក្មេងប្រុសអាវដៃវែងរលុងៗ ដើម្បីបិទបាំងទ្រូងរបស់នាងកុំឱ្យឃើញវាជាទ្រូងរបស់ស្រីក្រមុំ យុត្តិកាកំពុងរៀបចំបោសគ្រែរៀបខ្នើយដេក ពេលក្រឡេកមកឃើញច័ន្ទមានរង្វង់មុខស្រស់ផូរផង់យ៉ាងនេះក៏ភ្ញាក់ព្រើតដែរ

-អេ! មុខឯងស្អាតចំណាប់តែម្តង! ប្រហែលជាស្រីចោមរោមច្រើនណាស់ បើសិនជាឯងដឹងក្តីជាងនេះបន្តិចទៀតទៅ!

-អរគុណលោកបងដែលបានសរសើរខ្ញុំ!

-នែ៎! នៅឈរធ្វើភ្នែកស្លឹងដល់ណាទៀត? ម៉េចក៏មិនរកកន្លែងដេកពួនទៅ?

-អេ! គឺខ្ញុំកំពុងរកកន្លែងដេកនឹងណា មានប៉ៅអ៊ីទេបង? ខ្ញុំក្រាលដេកកៀនជញ្ជាំងខាងណោះវិញ ព្រោះខ្ញុំមិនចេះដេក គ្រែមួយពីរនាក់ទេ!

-អ៊ើៗ ដេកយ៉ាងម៉េចក៏ដេកទៅ នោះប៉ៅអ៊ីបត់នៅក្បែរតុសរសេរឯណោះ បងអស់កំលាំងណាស់សុំដេកមុនហើយ!

ច័ន្ទលាប៉ៅអ៊ី ចងមុងដេកផ្សេងម្នាក់ឯង។ យប់ស្ងាត់នាង លបមើលទៅយុត្តិកា ឃើញគេដេកបិទភ្នែកជិត នាងងើបដើរលបៗបំរុងបើកទ្វារបន្ទប់ចេញទៅក្រៅ ស្រាប់តែអ្នកកំលោះងើបអង្គុយឆ្វាក់ បើកភ្នែកក្រឡង់

-ច័ន្ទ? ឯងចង់ទៅណានឹង?

-បាទ...ខ្ញុំ...ចង់...ចង់ទៅបត់ជើងតូច!

-បើទៅបត់ជើង ម៉េចក៏ចាំបាច់ធ្វើឡេមឡើម? បើលោកពូទាស់ភ្នែក

ហើយមិនឱយឯងនៅបងមិនអាចជួយបានទេណា!

-បាទ! ខ្ញុំដឹងហើយបង!

ពេលយុត្តិកាប្រាស់ខ្លួនដេកវិញ។ ម៉ោង១២យប់យុត្តិកាដេកលក់យ៉ាងស្រួល នាងក្រមុំសំរស់នើតលប។ ចេញពីបន្ទប់ដេកចូលទៅក្នុងបន្ទប់ដាក់សៀវភៅរបស់លោកសាន ដែលមានតំកល់បញ្ជីការងារផ្សេង។នៅទីនោះ នាងរើមើលសំណុំលិខិតនិងបញ្ជីផ្សេង។ក្នុងទូម្តងមួយយ៉ាងប្រញាប់ប្រញាល់ ទើបតែមើលបានប៉ុន្មានដុំក្នុងថតទូទី១ ស្រាប់តែឮសិរីបជើង នាងក្រមុំគេចចេញវិញភ្លាម។ មីងធីអ្នកបំរើបើកទ្វារអើតមើលមកបន្ទប់សៀវភៅមិនឃើញមានអ្វីក៏រអ៊ូម្នាក់ឯង

-ប្រហែលជាកណ្តុរហើយ រើឱយរសិបតែម្តងរួចគាត់បិទទ្វារ ចូលដេកវិញ។ ច័ន្ទចូលទៅសំងំដេកលែងហ៊ានកំរើក។ ព្រឹកព្រលឹមមុននឹងទៅសាលាយុត្តិកាមកជួយជូតផ្ទះលាងឡានជាមួយច័ន្ទសិន នាងក្រមុំសំឡឹងគេភាំងបន្តិច

-លោកបងជាកូនក្មួយរបស់លោកប្រុស ម៉េចក៏ចាំបាច់មកជួយធ្វើការងារខ្ញុំ? ទុកឱយខ្ញុំធ្វើម្នាក់ឯងបានហើយ

យុត្តិកាញញឹមស្ងួត

-ជាសាច់ញាត្តិនោះយ៉ាងម៉េចដែរ? បងក៏ជាអ្នកស្នាក់អាស្រ័យដូចឯងដែរ បងជាអ្នកចំការម្នាក់ប៉ុណ្ណោះ ពេលរៀនចប់បងក៏ត្រូវរកលំនឹងរស់ដោយខ្លួនឯង មិនមែនចេះតែជ្រកកោននិងមាមីងមួយជីវិតនោះឡើយ! ចុះឯងវិញមានបានរៀនសូត្រនឹងគេទេ?

-បានរៀនដល់ត្រឹមថ្នាក់ទី១

អ្នកកំលោះបើកភ្នែកធំ។

-ស្អី? ឯងរៀនធ្លាក់រហូតឬ? បានជាធំប៉ុនឃ្លោករៀនថ្នាក់ទី១?

-មិនមែនខ្ញុំធ្លាក់រហូតទេបង! គឺខ្ញុំខ្ជិលរៀន!

-ឬកខ្ពស់ណាស់ហ្ន៎? កូនប្រុសបើមិនខំរៀនសូត្រ ទាល់តែកូនអ្នកមានអាងទ្រព្យទើបសម

-បាទ ប្រហែលមកពីខ្ញុំជាកូនអ្នកមានមែនក៏មិនដឹង

-បានហើយ និយាយជាមួយឯងយូរច្បាស់ជាឡប់តាមឯងមិនខាន បងទៅរៀនហើយ!

ច័ន្ទលួចរអ៊ូក្នុងចិត្ត (ហ៊ានថាខ្ញុំឡប់ផង? បងឯងឆោត ហើយល្ងង់ទៀតម៉េចក៏មិនថា?)

---

ស្រស់ម៉ារីឥឡូវមិនរម្យទម្យហួសដូចមុនទៀតឡើយ បរាជ័យដំបូងរបស់នាង ធ្វើឱយស្រីយល់ថាជាកូនស្រី មិនមែនចេះត្រឹមតែរៀបឬកពារដូចស្រីគ្រប់ល័ក្ខ ជាការគ្រប់គ្រាន់នោះទេ គឺត្រូវស្គាល់ពីសង្គមទាន់សម័យ ក្លាហានមានសមត្ថភាពជឿជាក់លើខ្លួនឯង សំដីរួសរាយ តែមិនភ្លើតភ្លើន។ ឥឡូវនេះនាងចេះស្លៀកពាក់ទាន់សម័យណាស់ គ្រាន់តែមិនខើចលេចលើលេចក្រោម

រៀនបើកឡានមកធ្វើការដោយខ្លួនឯងដោយមិនបាច់មានគេជូន! ការចេះតុបតែងធ្វើឱយសំរស់ស្រីកាន់តែស្រស់ប្រិមប្រិយឹទ្បើង មាណវីដើរចុះពីបន្ទប់ពេទ្យតំរង់ទ្បានរបស់នាង ដែលចតនៅក្រោមម្លប់ឈើ រួចទ្បើងបើកសំដៅទៅ មហាវិទ្យាល័យដែលយុត្តិការៀន ម៉ារីតែងឆ្លៀតទៅលេងជាមួយយុត្តិកា នៅទីនោះពេលនាងសំរាកការងារ ពួកគេរាប់អានគ្នាតាមភាពជាមិត្ត តែសំរាប់ម៉ារីវិញគឺនាងមានការចាប់អារម្មណ៏ទៅលើយុត្តិកាតែម្តង ព្រោះគេជាសុភាពបុរស ដែលគួរឱយនារីផ្ញើវាសនា កំលោះក្រមុំទាំងពីរ អង្គុយជជែកគ្នាលេងនៅតុម្ជូលក្រោមម្លប់ឈើមុខទីធ្លាសាលា យុត្តិកាសំឡឹងមុខ ម៉ារីទាំងទឹកមុខស្រងូត

-លោកជីន មិនសមនឹងធ្វើដូច្នេះសោះ ខ្ញុំដឹង!ថាគេផ្តាច់ពាក្យមិនរៀបការជាមួយអ្នកនាង ព្រោះគេចង់ទាក់ទង និង មុំ តែខ្ញុំមិនចង់ឱយប្អូនស្រីខ្ញុំរស់នៅជាមួយមនុស្សចិត្តដាច់ដូចគេនេះទេ!

ម៉ារីញញឹមស្រាល

-មិនដូចគ្នាទេបង! ជួនកាល គេស្រទ្បាញ់អ្នកនាងណាគ្រី គេអាចល្អជាមួយអ្នកនាង មិនដូចជាមួយខ្ញុំទេ!

យុត្តិកាក្រវីក្បាលតិចៗ

-តែមនុស្សហ៊ានធ្វើអ្វីគ្រប់យ៉ាង ដើម្បីតែបំណងរបស់ខ្លួនដូច្នេះ ពិបាកទុកចិត្តខ្លាំណាស់

ម៉ារីងើបមុខសន្សឹមៗ សំឡឹងយុត្តិកាភ្នែកស្រីពោរពេញដោយមនោ-សញ្ចេតនាជ្រាលជ្រៅណាស់

-តែខ្ញុំត្រេកអរណាស់ ដែលគេបញ្ឈប់ពិធីរៀបការនេះ ព្រោះខ្ញុំក៏មិនចង់រៀបការជាមួយគេដែរ! ហើយបុរសដែលខ្ញុំចងចាំជានិច្ច គឺបង! ខ្ញុំមិនអាចបំភ្លេចថ្ងៃដែលបងជួយសង្គ្រោះខ្ញុំនោះអស់មួយជីវិត!

យុត្តិកាធ្វើភ្នែកស្លឹមើលមុខនាង ម៉ារីធ្វើអ៊ឹមអៀនគេចមុខចេញ។ យុត្តិកាព្យាយាមបន្លប់ ព្រោះបេះដូងរបស់គេខ្ទេចខ្ទាំដោយសារណាគ្រីនៅថ្មីៗណាស់វាឈឺ ហើយចាំមិនងាយភ្លេចទ្បើយ អ្នកកំលោះគ្មានអារម្មណ៏ទទួលស្នេហ៏ថ្មីភ្លាមៗដូច្នេះទេ ទោះជាដឹងថាម៉ារីកំពុងទោរទន់មករកអ្នកក៏ដោយ មាណពគេចចូលថ្នាក់រៀនវិញ ដោយប្រាប់ម៉ារីថាត្រូវរៀនគួរបន្ថែម។ឆោមល្អក៏ត្រឡប់មកពេទ្យ ព្រោះត្រូវម៉ោងនាងចុះយាម ទៅដល់មុខបន្ទប់ប្រចាំការរបស់នាងស្រស់ម៉ារីភ្ញាក់ព្រើត ព្រោះពុទ្ធីកំពុងឈរចាំនាងក្បែរមាត់ទ្វារ ហើយញញឹមយ៉ាងស្រស់ទៀតផង

-សួស្តីអ្នកនាង

-ចាំសួស្តី

រួចនាងចង់ដើរចេញ តែពុទ្ធីស្ទុះមកពាំងពីមុខ

-ហេតុអ្វីក៏អ្នកនាងធ្វើដូចជាមិនចង់ជួបមុខខ្ញុំអញ្ចឹង?

ស្រីល្អមើលមុខគេបន្តិចមុខនាងស្ញប់ស្ញែងផង

-តើជួបមុខលោកបានប្រយោជន៏អ្វីទៅ? ខ្មៅនិងស ទឹកនិងភ្លើង ម្នាក់ដើរព្យាបាទគេ ម្នាក់ជាពេទ្យសង្គ្រោះគេដូចជាលោកនិងខ្ញុំ គឺមានទិសដៅខុសគ្នារួចស្រេចទៅហើយ!

ពុទ្ធីញាក់ស្មា

-តែអ្នកនាងកុំភ្លេចថាបើខ្ញុំជាភ្លើង ហើយអ្នកនាងជាទឹកនោះគឺល្អហើយ ព្រោះទឹកអាចពន្លត់ភ្លើងបានប្រហែលមកពីចរិយាទន់ភ្លន់ត្រជាក់ដូចទឹករបស់អ្នកនាងហើយ ដែលធ្វើឱយខ្ញុំចាប់អារម្មណ៍នោះ ថ្ងៃនេះខ្ញុំចង់មកសុំអ្នកនាងទៅញុំាបាយល្ងាចជាមួយខ្ញុំមួយពេល ខ្ញុំចង់ចាំអ្នកនាងនៅហាងវិមានសួគ៌ ព្រោះខ្ញុំធ្វើការនៅទីនោះ!

ឆោមស្រស់ជ្រួញចិញ្ចើមបន្តិច

-លោកគិតថា ខ្ញុំយល់ព្រមឬ?

អ្នកលេងរូបស្រស់ ញញឹមលូកដៃជ្រែងក្នុងហោប៉ៅ

-ប្រហែលជាព្រម! ព្រោះបើអ្នកនាងមិនទៅប្រាកដជាស្តាយក្រោយព្រោះមនុស្សអាក្រក់ដូចខ្ញុំគ្មានអ្វីដែលមិនហ៊ានធ្វើនោះទេ! ហើយខ្ញុំធ្វើបានគ្រប់យ៉ាងទៀតផង! ដូចជាចាប់អ្នកនាងម្តងទៀត ឬក៏សម្លាប់យុត្តិកាអ្នកមានគុណរបស់អ្នកនាងចោលឬក៏...ណ្ហើយខ្ញុំមិនបាច់រៀបរាប់ច្រើនពេកទេមែនទេ? កុំភ្លេចណា! ម៉ោង៤កន្លះជួបគ្នា

គេដើរចេញទៅទាំងហួចគ្រលួចហាក់ដូចជាសប្បាយចិត្តណាស់ ម៉ារីសំឡក់តាមក្រោយទាំងក្តាញ់រអ៊ូម្នាក់ឯង

-មនុស្សអីក៏ខុសគេយ៉ាងនេះ?

នៅក្នុងហាងរបស់កាណាន កំលោះអ្នកលេងរូបសង្ហា កំពុងកុម្ម៉ង់ម្ហូបពិសេសៗដាក់ពេញតុរួចជាស្រេចរង់ចាំម៉ារី អ្នកបំរើតុសើចញឹមៗ

-លោកបង ថ្ងៃនេះត្រូវឆ្នោតមែនទេ? បានជាមកដើរតួធ្វើជាភ្ញៀវហើយកុម្ម៉ង់ម្ហូបច្រើនយ៉ាងនេះ?

ពុទ្ធីសើចស្រស់

-ល្ងាចនេះខ្ញុំណាត់មិត្តនារីរបស់ខ្ញុំ មកហាងរបស់យើងណា៎! ឯងទៅប្រាប់ចុងភៅផងម្ហូបថ្ងៃនេះត្រូវបញ្ចេញឱយអស់ថ្វីដៃឮទេ!

-អូ ខ្ញុំស្មានតែលោកបងមិនចេះមានមិត្តស្រីទេតើ ព្រោះនារីៗនៅកន្លែងយើងគគោកមិនឃើញរវីរវល់សោះ!

-មកពីមិនទាន់ពេញក្នុងចិត្តទេដឹង? ឥឡូវខ្ញុំជ្រើសរើសបានហើយ! នែឯងកុំសួរច្រើនពេក ឆាប់ទៅលើកម្ហូបបណ្តើរៗមក!

កាណានបើកឡានមកឈប់មុខហាង បើកទ្វារឡានចុះ ម៉ារីក៏កំពុងចុះពីឡានរបស់នាងដែរ នាងសុខចិត្តមកតាមការណាត់ ព្រោះខ្លាចពុទ្ធីធ្វើបាបយុត្តិកា ពេលនោះខ្យល់បក់យ៉ាងខ្លាំងផាត់ស្បៃគ្របស្មារបស់នាង ប៉ើងទៅគ្របមុខកាណានតែម្តង ធ្វើឱយគេខឹងណាស់កន្ត្រាក់ស្បៃចេញ បើកភ្នែកធំៗ

-ចង្រៃយក៏!

ម៉ារីរត់មកដល់ល្មម

-សុំទោសលោក ស្បៃនាងខ្ញុំប៉ើងមកព្រោះខ្យល់ខ្លាំងពេក!

កាណានភាំងនិងសំរស់ស្រស់ស្រទន់របស់ឆោមល្អគេខំសើចបន្លប់ឬកពាររច្រឡោតរបស់គេ

-អូ! មិនអីទេអ្នកនាង! ណេះ! ខ្ញុំជូនកន្សែងវិញ

នាងក្រមុំលូកដៃទទួល ស្រាប់តែកាណានបន្លំចាប់ដៃនាង ដៀងភ្នែកញញឹមរបៀបរាយអន្ទាក់ស្នេហ៍ ព្រោះឃើញនាងចូលមកក្នុងរង្គសាលដូច្នេះ គិតថាប្រហែលជានារីហក់លោត គេជាថៅកែទីនេះស្រាប់ ច្បាស់ជាងាយទាក់ទងណាស់ ម៉ារីភ្ញាក់ព្រើត រំប្រែទឹកមុខទាញស្បៃពីដៃកាណានយ៉ាងរហ័ស រួចដើរតំរង់ទៅផ្នែកភោជនីយដ្ឋានដែលនៅជាន់ខាងក្រោមយ៉ាងលឿន កាណានខំស្ទុះតាម

-អ្នកនាង១

នាងក្រមុំដើរយ៉ាងលឿនមិនខ្វីងាក ពុទ្ធីឃើញម៉ារី ស្ទុះមកទទួលភ្លាមរួចទាញកៅអីឱយនាងដោយយកចិត្តទុកដាក់

-សុំអញ្ជើញអ្នកនាង

ស្រស់ស្រីអង្គុយចុះឃើត១សំឡក់គេទ្រង់ខ្នាញ់

-លោកសប្បាយចិត្តណាស់មែនទេ? អ្វីដែលធ្វើដោយបង្ខិតបង្ខំនោះវាមិនផុរចេញពីទឹកចិត្តពិតប្រាកដទេលោក!

ពុទ្ធីបាត់បង់អស់ភាពញញឹមដ៏ស្រស់ដែលគេធ្លាប់មាន គេចាក់ទឹកក្រូចឱយនាងបណ្ដើរ ញញឹមស្ងួត

-ខ្ញុំគ្រាន់តែជាកំទេចសំរាមក្នុងលំហនៃផែនដីនេះ! តំរេះវិជ្ជាមិនជ្រៅជ្រះ! ទ្រព្យសម្បត្តិគ្មាន ពូជអំបូរ! កិត្តិយស! បុណ្យស័ក្តិក៏គ្មានទាំងអស់ ខ្ញុំមានលទ្ធភាពអី សុំទឹកចិត្តពិតប្រាកដពីអ្នកនាងដែលជាបុត្រីក្នុងវណ្ណៈខ្ពង់ខ្ពស់បាននោះ? ខ្ញុំមានតែព្រមទទួលទឹកចិត្តក្លែងក្លាយបែបនេះហើយ!

ម៉ារីបាត់មាត់ឈឹង ខណៈនោះអ្នកបំរើលើកម្ហូបមកដាក់ថែមទៀត លួចមើលមុខម៉ារីរួចលាន់មាត់

-មិត្តស្រីរបស់លោកបងស្អាតណាស់! អញ្ចឹងបានជាមិនដែលឃើញបងវិលវល់នឹងនារី១នៅទីនេះ

ពេលអ្នកបំរើតុថយចេញទៅ ម៉ារីខាំមាត់ដាក់ពុទ្ធី

-អ្នកណាជាមិត្តស្រីរបស់លោក?

-ខ្ញុំគ្រាន់តែខ្ចីអ្នកនាងអួតគេបន្តិចទេតើ បើអ្នកនាងមិនពេញចិត្ត ចាត់ទុកថាខ្ញុំឆ្កួតតែម្នាក់ឯងទៅចុះ!

ម៉ារីធ្វើហ៊ឹះ

-នឹកឃើញយ៉ាងម៉េចបានជាណាត់ខ្ញុំមកញ៉ាំបាយនៅទីនេះ!

-គ្មានគិតយ៉ាងម៉េចទេ! គ្រាន់តែអផ្សុកចង់បានមិត្តនារីម្នាក់កំដរពេលញ៉ាំបាយ! តែប៉ុណ្ណឹងឯង! សូមអញ្ជើញអ្នកនាង ខ្ញុំហៅម្ហូបច្រើនណាស់ណា!

ខណៈនោះកាណាន ចូលមកដល់ល្មម គឺគេតាមមករកម៉ារី ឃើញនាងនៅអង្គុយញ៉ាំបាយជាមួយពុទ្ធី កាណានភ្ញាក់ព្រើត

-អូ! ពុទ្ធីមានមិត្តស្រីពីអង្កាលហ្ន៎? ធ្វើការជាមួយគ្នាយូរហើយ ខ្ញុំទើបតែដឹង! ខ្ញុំសុំស្គាល់អ្នកនាងខាងណេះផងបានទេ!

ពុទ្ធីញញឹមស្ងួត

-បាទ! នាងគឺអ្នកគ្រូពេទ្យ ម៉ារីនោះអី លោកថៅកែប្រាកដជាធ្លាប់ឮឈ្មោះនាងហើយ គ្រាន់តែមិនទាន់បានស្គាល់មុខប៉ុណ្ណោះ!

កាណានព្ញតែម៉ារីធ្វើភ្នែកស្លឺ នាងស្រស់ស្អាតយ៉ាងនេះ ម៉េចក៏ជីនមិនពេញចិត្តទៅវិញ?

-ណ្ហើយចុះខ្ញុំមិនហ៊ានរំខានទេ លាសិនហើយអ្នកនាង! ពុទ្ធី!

រួចគេដើរចេញទៅ ទាំងភ្នែកលួចដៀងមើលមុខម៉ារីមិនឈប់ ពុទ្ធីប្រែទឹកមុខបន្តិច

-កាណានជាចៅកែខ្ញុំ គេជាមិត្តនឹងជីនទៀតផងតែគេជាព្រាននារីម្នាក់ អ្នកនាងគួរប្រយ័ត្នជាមួយគេ កុំភាក់ទាក់ព្រោះមិនមានប្រយោជន៍អ្វីទេ!

ស្រស់ធីតាជ្រួញចិញ្ចើម

-លោកនិងគេនៅកន្លែងតែមួយ! តើខ្ញុំគួរជឿថាអ្នកណាអាក្រក់អ្នកណាល្អ? ខ្ញុំព្រមមកជួបលោកពេលនេះ ព្រោះខ្ញុំខ្លាចលោកធ្វើបាបបងយុត្តិកា តែខ្ញុំសុំប្រាប់លោកថា បើលោកបង្ខំឱយខ្ញុំទាល់ច្រក ខ្ញុំមានតែសេចក្ដីស្លាប់ប៉ុណ្ណោះ!

អ្នកកំលោះធ្លាក់ទឹកមុខ តែញញឹមទាំងបង្ខំ

-មែន! ខ្ញុំមិនមែនជាមនុស្សល្អស្អីនោះទេ! ខ្ញុំធ្វើការឱយគេដើម្បីប្រាក់ លក់កំលាំងនិងជីវិត តែខ្ញុំមិនធ្លាប់បានបោកប្រាស់ស្រីណាម្នាក់ឡើយ! ខ្ញុំស្ដាយបំផុត គឺពេលដែលខ្ញុំបានធ្វើឱយអ្នកនាងបាត់បង់កិត្តិយស ខ្ញុំចង់សងអ្វីៗដែលអ្នកនាងបាត់បង់ទៅតែមិនអាចទេ ព្រោះខ្ញុំគ្មានអ្វីស័ក្តិសមនឹងសងអ្នកនាង!

ស្រស់ស្រីមើលមុខគេយ៉ាងមុត

-បើលោកគិតថាចង់ល្អចំពោះខ្ញុំហេតុអ្វីក៏...

-បង្ខិតបង្ខំអ្នកនាងពេលនេះមែនទេ? ខ្ញុំក៏មិនដឹងដែរថាមូលហេតុអ្វី! តែខ្ញុំពិតជាគ្មានបំណងអាក្រក់ចំពោះអ្នកនាងឡើយ! កុំភ្លេចណា រាល់ល្ងាចថ្ងៃអាទិត្យ ខ្ញុំរង់ចាំអ្នកនានៅមាត់ទន្លេត្រង់ខ្លូសលំហែ ខ្ញុំនៅចាំរហូតទាល់តែអ្នកនាងមក! ខ្ញុំចង់ជួបមុខអ្នកនាង! និយាយលេងជាមួយអ្នកនាង! តែប៉ុណ្ណឹងទេ! ម៉ារីដកដង្ហើមធំមិនចេញស្ដី!

--------------------------

យប់ជ្រៅណាស់ហើយ ពពករសាត់មីរដេរដាស ដួងច័ន្ទ និង តារាបាត់អស់រស្មីជាសញ្ញាជិតភ្លៀង ខ្យល់បក់ត្រជាក់ស្រឹបស្រៀវរងាដល់ឆ្អឹង យុត្តិកាស្ទុះងើបពីកៅអី ព្រោះគេកំពុងនៅអង្គុយមើលមេរៀននៅឡើយ មិនទាន់ចូលសំរាកទេ អ្នកកំលោះដើរទៅយកភួយក្រាស់របស់គេមកដណ្ដប់ឱយច័ន្ទព្រោះឃើញគេដេកអោបដៃក្រវៀនបែបរងា តែនាងក្រមុំគ្រាន់តែសំងំមិនទាន់គេងលក់ទេ

ច័ន្ទបើកភ្នែកក្រឡង់ស្រវាភួយទាំងញញឹម

-អរគុណបង! ដែលគិតបារម្ភពីខ្ញុំ អ្នកនៅក្នុងផ្ទះនេះមានតែបងម្នាក់ទេ ល្អចំពោះខ្ញុំនោះ!

មាណពសង្ហាអង្អែលសក់នាងថ្នមៗ

-ព្រោះបងតែងតែចាត់ទុកឯង ដូចប្អូនប្រុសរបស់បងអញ្ចឹង បើគេនៅ

មានជីវិត និមិត្តគេធំជាងច័ន្ទឯងទៅទៀត!

ច័ន្ទបើកភ្នែកក្រឡង់

-ប្អូនប្រុសបងស្លាប់យូរហើយឬ?

-គេលង់ទឹកស្លាប់តាំងពីអាយុ៣ឆ្នាំ សូម្បីតែសាកសពក៏រកមិនឃើញដែរ អ្នកម៉ែកើតទុក្ខរហូតសព្វថ្ងៃ ច័ន្ទបងមានរឿងមួយចង់សួរឯងបន្តិច ជួយឱយយោបល់បងផងមើល!

-រឿងអីបង?

-ច័ន្ទ បើនារីម្នាក់គេប្រគល់ផ្កា១ទងឱយយើង! ផ្កាដំណាងឈ្មោះគេ! ដំណាងអ្វីៗគ្រប់យ៉ាង! តើវាដំណាងដួងព្រលឹងស្មោះសររបស់គេដែរឬទេ?

ច័ន្ទសំឡឹងមុខយុត្តិកាហាក់សញ្ជឹងគិតបន្តិច

-អ្នកនាងណាត្រីមែនទេបង? ខ្ញុំធ្វើម៉េចអាចឆ្លើយប្រាប់បងបាននោះ បើខ្ញុំមិនមែនជាមនុស្សស្រីផង!

អ្នកកំលោះសង្ហាបន្លូរដង្ហើមធំមិនចេញស្តីរួចក៏ដើរទៅរៀបចំកន្លែងដេក ព្រោះយប់កាន់តែជ្រៅ។ ពេលមាណពដេកលក់ស៊ប់ច័ន្ទនាងលួចចេញទៅបន្ទប់សៀវភៅលោកសានវីរុះ តែនាងប្រញាប់ពេក រកមិនទាន់ឃើញអ្វីដែលនាងត្រូវការឡើយ ស្រស់ស្រីមិនហ៊ាននៅយូរក៏លបៗចូលមកដេកវិញ តាំងចិត្តថានាងត្រូវតែអត់ធ្មត់បំរើគេតទៅទៀត ដើម្បីបំណងនាងបានសំរេច។ ព្រឹកព្រលឹម ព្រះសុរិយារះរៀងបំព្រាងរស្មី ពណ៌មាសឆ្អិនឆ្អៅឯនាយបូព៌ាទិស បក្សាបក្សីហោះហើរច្រៀវច្រៃ ចាកទ្រនំស្វះស្វែងរកចំណី សព្វជីវិតក្នុងលោកក៏យក៏

ចាកនិទ្រាប្រកបការងារ ចិញ្ចឹមជីវិតដូចសព្វកាលសព្វវេលា ថ្ងៃនេះយុត្តិកាចូលទៅសំពះសុំលោកសាន ទៅសួរសុខទុក្ខម្តាយបានមួយអាទិត្យទាន់ពេលសំរាកពីការសិក្សា ត្រៀមខ្លួនប្រលងចេញជាសាស្ត្រាចារ្យ គេទៅជាមួយច័ន្ទលោកសានក៏អនុញ្ញាតិ ហើយលោកមានពាក្យខ្លះដាស់តឿនអ្នកកំលោះក្នុងពេលនេះតែម្តង

-ពូមានរឿងមួយចង់រំលឹកឯង កុំសូវជិតស្និទនិងមុំដូចមុនឮទេ? ខ្លាចជីនគេមិនសប្បាយចិត្ត ព្រោះគេបានមកពិគ្រោះជាមួយពូរួចហើយចង់ឱយចាស់ទុំចូលមកស្តីដណ្តឹងស្រីមុំឆាប់ៗនេះ! ពូសង្ឃឹមថាឯងមិនមែនជាមនុស្សស៊ីបាយបោកឆ្នាំងទេ!

ដំណឹងនេះប្រៀបដូចព្យុះបោកដួងចិត្ត យុត្តិកាឱយងងឹតសូន្យសុង ហ៊ឹងត្រចៀកង៉ឹងតែម្តង ទោះជាគេបានត្រៀមចិត្តត្រៀមកាយនិងទទួលហេតុការណ៍នេះរួចជាស្រេចក៏ដោយ ក៏បេះដូងគេនៅតែញាប់ញ័រនិងចុកចាប់រកថាមិនត្រូវ អ្នកកំលោះខំតាំងស្មារតីញញឹមទាំងត្រដរ

-បាទ! លោកពូមានគុណចំពោះខ្ញុំ! ខ្ញុំមិនអាចធ្វើខ្លួនជាមនុស្សរមិលគុណបានឡើយ ខ្ញុំមានតែជួយត្រេកអរ ដែលអូនមុំមានភ័ព្វសំណាងល្អរស់នៅលើគំនរទ្រព្យសម្បត្តិព្រមទាំងកិត្តិយស!

-ប្រសើរណាស់ បើឯងយល់ច្បាស់ហើយ ពូមិនបាច់និយាយអ្វីច្រើនទេ!។

យុត្តិកានាំច័ន្ទទៅលេងចំការស្រុកកំណើតរបស់គេនៅក្បៀនស្វាយ ដើម្បីរំសាយទុក្ខកង្វល់ក្នុងចិត្តរបស់គេផង... និងបានជួយកិច្ចការម្តាយខ្លះផង មីង

ធៀនត្រេកអរណាស់ពេលបានកូនមកលេងដូច្នេះ ហើយគាត់ក៏មាននិស្ស័យស្រឡាញ់អាណិតច័ន្ទណាស់ អ្នកទាំងពីរជួយដាំដើមមៀននិងល្មុតអ្នកមីងធៀន រួចនាំគ្នាទៅអង្គុយលេងឱយត្រជាក់ខ្លួននៅមាត់ទឹក ពួកគេអង្គុយសំយុងជើងលើមែកត្របែកម្ខាងម្នាក់ ច័ន្ទផ្លុំប្រដាប់ក្មេងលេង ដែលផ្លុំទៅចេញជាប៉េងប៉ោងអណ្ដែតត្រសែតពេញលំហដូចពពុះទឹកល្អមើលណាស់

-លោកបង១ទៅហើយ ពពុះ៧ពណ៌ស្អាតណាស់មាណពងើយមើលពពុះដែលហោះអណ្ដែតកាត់មុខគេរួចញញឹមស្ងួត

-ពពុះទឹកអណ្ដែតត្រសែតគ្មានគោលដៅ សេចក្ដីប្រាថ្នាហួសនិស្ស័យទាំងអស់នេះដូចគ្នាណាស់មែនទេច័ន្ទ? វាមិនខុសពីការយល់សប្ដិប៉ុន្មានទេ!

ច័ន្ទអង្គុយយោលយោគលើមែកឈើ

-ហ៊ឹស! មិនដឹងជាអ្នកទស្សនៈវិទូស្អីទេខ្ញុំសិស្សថ្នាក់ទី១ ធ្វើម៉េចស្ដាប់អត្ថន័យអត្ថរូប អត្ថរស និងការប្រៀបធៀបរបស់បងយល់?

យុត្តិកាមើលមុខច័ន្ទទ្រង់ភ្ញាក់

-នែ! ក្រែងឯងរៀនត្រឹមថ្នាក់ទី១ ម៉េចក៏ចេះនិយាយហួហែម្ល៉េះ?

នាងក្រមុំ ភ្ញាក់ខ្លួនសើចបន្ទប់

-ខ្ញុំរៀននិយាយតាមគេតាមឯងទៅណាលោកបងទុកបង្អួតស្រី១ព្រោះខ្ញុំដឹងថាស្រី១គេមិនចូលចិត្តប្រុសល្ងង់ទេ!

ច័ន្ទរវល់តែនិយាយឆ្កាដៃឆ្កាជើង ភ្លេចខ្លួនក៏ធ្លាក់ពីលើដើមត្របែក បះដៃបះជើង នាងក្រមុំថ្ងូរហ៊ឺះអង្អែលត្រគាកញាប់ដៃយុត្តិកាហក់ចុះមកជួយគ្រានាងឡើង

-យ៉ាងម៉េចទៅហើយច័ន្ទ? នឹងហើយពូកែឆ្កាដៃឆ្កាជើងពេក! ទៅផុះរួចទេ?

-អត់រួចទេបង ថ្លោះជើងទៅហើយ!

-ណ្ហើយតោងកបងមក ចាំបងអៀវទៅផ្ទះ!

យុត្តិកាអៀវច័ន្ទកាត់ចំការឡើងបែកញើសឯក្រមុំខិលបែរជា ញញឹមស្រស់លៀនអណ្ដាតយ៉ាងសប្បាយចិត្តទៅវិញ ព្រោះកុហក់ឱយយុត្តិកាអៀវឡើងបាក់ញើស ការពិតនាងមិនបានថ្លោះជើងសោះ ពេលនោះជួនជាយុត្តិកាងាកមកក្រោយឃើញទាន់ ហួសចិត្តក៏ទម្លាក់នាងចុះព្រួស ចំអាចម៍ឆ្កែប្រឡាក់ខោអស់ ច័ន្ទស្រែកយ៉ៃ

-អូយ! លោកបង ម៉េចក៏ធ្វើបាបខ្ញុំបែបនេះ?

-ស្រួលទេ? មនុស្សខូចចង់បោកប្រើផង! សុំទោសទៅមុនហើយ មិនដើរជាមួយទេស្អុយអាចម៍ឆ្កែណាស់!

យុត្តិកាដើរទៅបាត់ ច័ន្ទស៊ុះងើបទន្រ្ទាំជើងម្នាក់ឯង

-ហ៊ឹះ! លោកបង ខ្ញុំនឹងទារជម្ងឺចិត្តវិញឱយទាល់តែបាន ចាំមើលចុះ!

ថ្ងៃនេះពូនរងស្អែរួចយុត្តិកា សន្យានាំច័ន្ទទៅញ៉ាំបាញ់ឆែវឆ្ងាញ់ នៅហាងមាត់ទឹក ពេលដែលអ្នកកំលោះ រវល់ទៅងូតទឹកជំរះខ្លួន នាងក្រមុំលប១ចូលទៅលួចលុយក្នុងហោប៉ៅអស់រលីង រួចខ្ទប់មាត់សើចម្នាក់ឯង។ ពេលញ៉ាំបាញ់ឆែវច័ន្ទហៅទឹកផ្លែឈើផងទឹកដោះគោឆៅផង រួចក៏គេចប្រាប់យុត្តិកា ថា

ទៅបន្ទប់ទឹក តែនាងទៅពួនសើចក្នុងចំការតែម្នាក់ឯងទៅវិញ។ អ្នកកំលោះសង្ហាញ៉ាំផ្អែត រកប្រាក់ឱ្យគេមិនឃើញ ច័ន្ទក៏មិនឃើញមកពីបង្គន់ ទើបដឹងថាចាញ់កលនាយល្អិត យុត្តិកាត្រូវបញ្ចាំនាឡិកាគេយករួចខ្លួនសិន។ អ្នកកំលោះលបៗទៅពីក្រោយច័ន្ទ ដែលកំពុងឈរផ្អែកគល់ឈើសើចព្រាយតែឯងនោះ ទះកំប៉េះគូថនាង១ដៃអស់ទំហឹង ស្រស់ស្រីឈឺច្រឡោត លោតកញ្ឆេង

-អូយ! លោកបង ម៉េចក៏លេងអាក្រក់ម្ល៉េះ?

-អ្នកលេងអាក្រក់មិនមែនបងទេ! ឯងលេងអីឆ្កួតៗអញ្ចឹង? ដឹងថាបងខ្មាស់គេប៉ុណ្ណាទេ?

ស្រស់ស្រីក្លែងកាយ ក្របួចមាត់ដាក់អ្នកកំលោះ

-នេះគេហៅថាល្បិចសងសឹកណាលោកបង!

-សងសឹកហ្អី? ត្រូវការមួយដៃទៀតទេ?

ច័ន្ទក្ដោបត្រគាករត់ត្របាញ់ជើញ

-អត់ទេ! លោកបង! អត់ទេ...

យុត្តិកាឈរសើចកក្អឹក គេទាំងពីរកំពុងសាងអនុស្សាវរីយ៍ជាច្រើនជាមួយគ្នាដោយមិនដឹងខ្លួន។